# រឿង ទុង និង ត្រី



# រឿង ទុង និង ត្រី



រៀបរៀងដោយ លោក ឌីន សុន

គូរដោយ លោក សំ សារ៉ាត

បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)

ពេលព្រលឹមស្រាងៗ គេឃើញទុងមួយហ្វូង អាស្រ័យនៅលើដើមឈើសាខាធំមួយ ។ ក្នុងនោះ មានទុងញីឈ្មោលមួយគូកំពុងពិគ្រោះគ្នា  មុនពេលចេញស្វែងរកចំណីអាហារ ។







ពេលនោះ ទុងឈ្មោលនិយាយ « អូននៅក្រាបនឹងសំបុកនេះចុះ ដើម្បីអោយកូនៗ យើងឆាប់ញាស់ បងចេញទៅរកចំណីនឹងគេហើយ! »។ លាប្រពន្ធរួច ទុងឈ្មោលកាងស្លាបហើរចេញពីសំបុកភ្លាម ។ មេទុងតាមមើលប្តីទាំងចិត្តអាឡោះអាល័យ ។





ពេលកំពុងហើរនាំមុខគេ នៅឯលំហអាកាស ទុងឈ្មោលទទះស្លាប ភ្នែករំពៃរកមើលបឹងនៅខាងក្រោម ។
លុះហើរកាន់តែឆ្ងាយទៅៗ ទុងឈ្មោលក៏ឃើញបឹងធំមួយមានទឹកថ្លា  ហើយមានផ្កាព្រលិតរីកដេរដាស។





មួយសន្ទុះក្រោយមក ស្រាប់តែទុងឈ្មោលក្រឡេកឃើញត្រីក្អិតមួយ ក៏ស្ទុះហក់ដេញចឹក ត្រីក្អិតនោះភ្លាម ។





លុះចឹកត្រីក្អិតបានហើយ ទុងគិតថា « យី ! កូនត្រីក្អិតនេះតូចណាស់ ពុំសមនឹងអញដែលជាបក្សីធំសោះ » ។





គិតឃើញដូច្នោះហើយ ទុងឈ្មោលក៏បើកចំពុះលែងកូនត្រីក្អិតនោះទៅក្នុងបឹងវិញ ។





ពេលលែងកូនត្រីក្ដិតរួច ទុងឈ្មោលហែលទៅមុខទៀត វាក៏ក្រឡេកឃើញត្រីចង្វាមួយ ។ ទុងគិតថា “ ត្រីចង្វានេះក៏តូច ពុំទាន់សមនឹងអញដែលជាបក្សីធំដែរ ” ។ គិតហើយទុងក៏ហែលហួសទៅ ។ ហែលទៅមុខបានបន្តិច ទុងក៏ក្រឡេកឃើញត្រីចង្វាភ្លៀងមួយទៀត ។ មិនបង្អង់យូរ ទុងក៏ហក់ហែលដេញតាមចឹកត្រីចង្វាភ្លៀងនោះ ។





ថ្ងៃរសៀលកាន់តែទាបទៅៗ ឯទុងក៏នៅតែស្វែងរកចាប់ត្រីធំពុំបាន ។ ព្រួយចិត្តណាស់ ទុងខំសម្លឹង ងាកឆ្វេង ងាកស្តាំ តែនៅតែរកមិនបានត្រីធំមួយឡើយ ។





ដោយក្ដីស្រេកឃ្លាន  ទុងទទះស្លាបហើរទាំងអស់សង្ឃឹម  ទៅទំលើមែកឈើងាប់មួយក្បែរមាត់បឹង រួចសម្លឹងមើលផ្ទៃទឹកពុំប៉ប្រិចភ្នែកឡើយ ។ ទុងសម្លឹងមើលផ្ទៃទឹកបណ្ដើរ ស្រមៃឃើញត្រីក្អិត ត្រីចង្វា និង ត្រីចង្វាភ្លៀងដែលវាចាប់បានហើយ  លែងទៅវិញ  ដោយក្ដីទុក្ខព្រួយ និងសោកស្ដាយ ។





លុះថ្ងៃលិច ទុងទទះស្លាបលាន់ ភិបៗ!  ហើយហើរត្រឡប់ទៅកាន់លំនៅស្ថានរបស់ខ្លួនវិញ
ទាំងបង្ខំចិត្ត  ដោយគ្មានចំណីអាហារក្នុងពោះ និងគ្មានបញ្ញើផ្ញើប្រពន្ធដែលកំពុងក្រាបពងឡើយ ៕

—— ចប់ ——



# រឿង ទុង និង ត្រី

ដកស្រង់ចេញពី សៀវភៅគតិលោក ភាគ៤
គូររូបដោយ លោក សំ សារ៉ាត
រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)
បោះពុម្ពឆ្នាំ២០០៥

